សប្តាហ៍ទី 1

ការបង្កើតផ្ទៃមេឃ និងផែនដី

ពិភពលោកដ៏ស្រស់ស្អាតដែលព្រះជាម្ចាស់បង្កើត

រឿងក្នុងព្រះគម្ពីរ

ព្រះជាម្ចាស់បានចំណាយពេល ៦ថ្ងៃ ដើម្បីបង្កើតផ្ទៃមេឃ ផែនដី សមុទ្រ រុក្ខជាតិ ព្រះអាទិត្យ ព្រះច័ន្ទ ផ្កាយ និងសត្វគួរឱ្យស្រឡាញ់ជាច្រើន ហើយទ្រង់ក៏បានឈប់សម្រាកនៅថ្ងៃទី៧។

តស់! ពួកយើងនាំគ្នាតុបតែងចានក្រដាស ឱ្យទៅជាពិភពលោកដ៏ស្រស់ស្អាតដែលព្រះជាម្ចាស់បានបង្កើតទាំងអស់គ្នា!

អត្ថបទគម្ពីរៈ
[លោកុប្បត្តិ ១:១-៣១]

សមិទ្ធផលសម្រេច



វត្ថុបំណង

- ស្វែងយល់ពីពិភពលោកដែលព្រះជាម្ចាស់បានបង្កើត។
- ចេះបែងចែក និងគូរបង្ហាញពីពេលថ្ងៃ និងពេលយប់ សមុទ្រ និងផែនដី។
- ប្រើប្រាស់សម្ភារៈផ្សេងៗ ដើម្បីតុបតែងដោយភាពច្នៃប្រឌិត។

សម្ភារៈ



របៀបធ្វើ

1 ការគូរពេលថ្ងៃ និងពេលយប់

ត្រូវចែកចានក្រដាសជាពីរចំណែក រួចលាបពណ៌មួយចំហៀងជាពេលថ្ងៃ និងមួយចំហៀងទៀតជាពេលយប់។



2 ការគូរដី និងសមុទ្រ

ត្រូវចែកចានក្រដាសផ្នែកខាងក្រោមជាពីរចំណែក រួចលាបពណ៌មួយចំហៀងជាសមុទ្រ និងមួយចំហៀងទៀតជាដី។



3 ការតុបតែងអ្វីដែលព្រះបានបង្កើត

ត្រូវកាត់អ្វីៗដែលព្រះបានបង្កើត រួចបិទ។
(រុក្ខជាតិ សត្វ សត្វសមុទ្រ ផ្កាយ)



4 បញ្ចប់ការតុបតែង ដោយកាត់រូបភាពបិទ

កាត់រូបភាព រួចបិទ បង្កើតជាសមិទ្ធផលផែនដីដែលព្រះបានបង្កើត។



ការពង្រីកសកម្មភាព

- ស្វែងរកអ្វីដែលព្រះបានបង្កើត
  ស្វែងរកអ្វីដែលព្រះជាម្ចាស់បានបង្កើតនៅឯផ្ទះ ឬនៅថ្នាក់រៀន។
- រឿងរ៉ាវនៃការបង្កើតរបស់ខ្ញុំ
  បើសិនជាអ្នកអាចបង្កើតអ្វីមួយថ្មីបាន តើចង់បង្កើតអ្វី? សូមបង្ហាញតាមរយៈការគូររូប។

Tip សម្រាប់គ្រូ

- សូមរៀបរាប់ពីការបង្កើតតាមលំដាប់លំដោយ។ ពន្លឺ និងងងឹត, មេឃ និងសមុទ្រ, ដី និងរុក្ខជាតិ, ព្រះអាទិត្យ, ព្រះចន្ទ, ផ្កាយ, សត្វ,មនុស្ស។
- «តើហេតុអ្វីបានជាព្រះជាម្ចាស់បង្កើតថ្ងៃនិងយប់, ដីនិងសមុទ្រ?» សូមស្តាប់ រួចចែកចាយពីគំនិតរបស់កុមារ។